ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១០៥២៩ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៦

## សូមគោរពជូន
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ ៖** របាយការណ៍ប្រចាំសប្តាហ៍ស្តីពី សភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧ គិតត្រឹមថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦ មានដូចតទៅ ៖

### I. លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ ៖

**១- ការងារដាំដុះ ៖**

ក- ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៣ ០០១ ០៨៥ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោក្របីចំនួន ២៦៥ ១០២ហ.ត (ស្មើនឹង ៨,៨៣%) និងដោយគ្រឿងយន្តកសិកម្មចំនួន ២ ៧៣៥ ៩៨៣ហ.ត (ស្មើនឹង ៩១,១៧%) តិចជាងឆ្នាំមុន៥៥២ ៨០២ហ.ត។

ខ- សាបសម្រេចបានចំនួន ៥០ ៦១៩ហ.ត តិចជាងឆ្នាំមុន ២០ ៤៥៤ហ.ត។

គ- ស្ទូងនិងព្រោះសម្រេចបានចំនួន ២ ៥៩៩ ៥៨៦ហ.ត ស្មើនឹង ១០៤,៩៧%នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុន៣៧ ៦២៩ហ.ត ស្មើនឹង ៥,១៧%។

**២- ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៦** (ដូចមានតារាងជូនភ្ជាប់) ៖

ការងារប្រមូលផលស្រូវរដូវវស្សា រហូតមកដល់ពេលនេះ សម្រេចបានចំនួន ១ ៥៣០ ២០២ហ.ត លើផ្ទៃដីអនុវត្តសរុប ២ ៥៩៩ ៥៨៦ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៤ ៧១២ ៥០៩តោន លើសឆ្នាំមុន ៧០៣ ៦២២តោន។ ទិន្នផលគិតជាមធ្យម ៣,០៨០តោន/ហ.ត (សប្តាហ៍មុន ២,៩៧៦តោន/ហ.ត) លើសឆ្នាំមុន ៣៦៧គ.ក្រ/ហ.ត។

### II. ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧ (ដូចមានតារាងជូនភ្ជាប់) ៖

- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ២៣៦ ៤៩៧ហ.ត តិចជាងឆ្នាំមុនចំនួន ៩៨ ៩៣៨ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន ៩ ២១៩ហ.តស្មើនឹង ៣,៩០% និងដោយគ្រឿងយន្តចំនួន ២២៣ ០០១ហ.តស្មើនឹង ៩៤,២៩%
- សាបបានសរុបចំនួន ២១៩ហ.ត តិចជាងឆ្នាំមុនចំនួន ៥៨៧ហ.ត
- ស្ទូងនិងព្រោះសម្រេចបានចំនួន ១៨២ ២៩៦ហ.ត ស្មើនឹង ៤២,០៧%នៃផែនការ ៤៣៣ ៧៥៥ហ.ត តិចជាងឆ្នាំមុន ១១៣ ៨៥៥ហ.ត មូលហេតុដោយទឹកស្រកយឺតហើយខេត្តខ្លះពុំទាន់បានអនុវត្តនៅឡើយ។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 , Preah Norodom Sangkat Tonle Basak Khan Chamkamon B V D, Phnom Penh. Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 217-320

**III. ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧** (ដូចមានតារាងជូនភ្ជាប់)÷

ក- ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន ១៥ ១១៧ហ.ត ស្មើនឹង ២០,៦៤% នៃផែនការ ៧៣ ២៤៩ហ.ត តិចជាងឆ្នាំមុន ៨ ៧៦៣ហ.ត។

ខ -ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន ២ ០៣៨ហ.ត ស្មើនឹង ១៤,៤៣% នៃផែនការ ១៤ ១២១ហ.ត តិចជាងឆ្នាំមុន ២ ១៨៩ហ.ត។

**IV. សេចក្តីសន្និដ្ឋាន**

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ បានបញ្ចប់ជាស្ថាពរហើយ ដោយសម្រេចបាន ២ ៥៩៩ ៥៨៦ហត ស្មើនឹង ១០៤,៩៧% នៃផែនការ ២ ៤៧៦ ៤៤៦ហត លើសឆ្នាំមុនចំនួន ៣៧ ៦២៩ហត។ មកទល់ពេលនេះ ប្រជាកសិករបាននិងកំពុងជំរុញការងារប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម ក្នុងនោះ ល្បឿននៃការប្រមូលផលស្រូវរដូវវស្សាគឺស្មើនឹង **៥៨,៨៦%** នៃផ្ទៃដីអនុវត្ត **២ ៥៩៩ ៥៨៦**ហត ដែលទទួលបានទិន្នផលគិតជាមធ្យម ៣,០៨០តោន/ហ.ត និងកំពុងខិតខំជំរុញការដាំដុះដំណាំរដូវប្រាំងជាបន្តទៅទៀត។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តណែនាំជាប្រចាំដល់ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត អង្គភាពជំនាញទាំងអស់ត្រូវចាត់វិធានការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព ជំរុញការជីកស្តារស្រះប្រឡាយ អាងស្តុកទឹក រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ ព្រមទាំងបន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន សមាគមម៉ាស៊ីនកិនស្រូវនិងសហគមន៍កសិកម្មក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមទាំងឡាយក្នុងកាលៈទេសៈដែលកសិករកំពុងតែប្រមូលផលស្រូវចុងរដូវវស្សានេះ ក៏មានការបន្ទាបតម្លៃស្រូវនៅទីផ្សារដែលធ្វើឱ្យប៉ះពាល់ទៅលើចំណូលរបស់កសិករផងដែរ។ ដោយឡែក ក្រសួងបន្តចុះពិនិត្យតាមដានការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និងចាត់ក្រុមអន្តរាគមន៍ចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្តជាប់ជាប្រចាំ។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

  "ដើម្បីជូនជ្រាប"
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ ២០១៦

(គិតត្រឹមថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | ភាគរយ (%) | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 247,015 | 173,647 | 2.673 | 464,163 | 70.30 | 05-12-2016 |
| 02 | បាត់ដំបង | 289,567 | 131,564 | 3.360 | 442,055 | 45.43 | 06-12-2016 |
| 03 | កំពង់ចាម | 89,861 | 37,874 | 3.425 | 131,432 | 48.74 | 24-11-2016 |
| 04 | កំពង់ឆ្នាំង | 124,409 | 50,281 | 2.713 | 136,392 | 40.42 | 06-12-2016 |
| 05 | កំពង់ស្ពឺ | 115,116 | 31,366 | 2.938 | 92,151 | 27.25 | 06-12-2016 |
| 06 | កំពង់ធំ | 215,526 | 143,597 | 2.611 | 374,938 | 66.63 | 06-12-2016 |
| 07 | កំពត | 138,388 | 52,408 | 8.437 | 442,169 | 37.87 | 06-12-2016 |
| 08 | កណ្ដាល | 35,329 | 10,522 | 3.656 | 38,470 | 29.78 | 05-12-2016 |
| 09 | កោះកុង | 10,503 | 6,848 | 2.745 | 18,797 | 65.20 | 06-12-2016 |
| 10 | ក្រចេះ | 33,072 | 30,363 | 2.040 | 61,941 | 91.81 | 06-12-2016 |
| 11 | មណ្ឌលគិរី | 23,608 | 20,903 | 2.656 | 55,517 | 88.54 | 07-12-2016 |
| 12 | ភ្នំពេញ | 10,291 | 1,180 | 2.900 | 3,422 | 11.47 | 29-11-2016 |
| 13 | ព្រះវិហារ | 82,398 | 67,726 | 2.926 | 198,195 | 82.19 | 05-12-2017 |
| 14 | ព្រៃវែង | 270,111 | 187,766 | 3.069 | 576,313 | 69.51 | 06-12-2016 |
| 15 | ពោធិ៍សាត់ | 115,984 | 89,086 | 3.123 | 278,216 | 76.81 | 28-11-2016 |
| 16 | រតនគិរី | 26,185 | 24,208 | 2.290 | 55,436 | 92.45 | 06-12-2016 |
| 17 | សៀមរាប | 186,735 | 133,585 | 2.618 | 349,788 | 71.54 | 06-12-2016 |
| 18 | ព្រះសីហនុ | 16,605 | 10,931 | 2.404 | 26,278 | 65.83 | 02-12-2016 |
| 19 | ស្ទឹងត្រែង | 28,678 | 28,678 | 2.500 | 71,695 | 100.00 | 06-12-2016 |
| 20 | ស្វាយរៀង | 168,528 | 78,042 | 2.857 | 223,001 | 46.31 | 06-12-2016 |
| 21 | តាកែវ | 197,444 | 107,642 | 3.431 | 369,279 | 54.52 | 06-12-2016 |
| 22 | ឧត្ដរមានជ័យ | 86,501 | 73,123 | 2.527 | 184,750 | 84.53 | 06-12-2016 |
| 23 | កែប | 3,597 | 2,616 | 3.180 | 8,319 | 72.73 | 06-12-2016 |
| 24 | ប៉ៃលិន | 5,825 | 1,616 | 2.800 | 4,525 | 27.74 | 23-11-2016 |
| 25 | ត្បូងឃ្មុំ | 78,310 | 34,630 | 3.040 | 105,267 | 44.22 | 25-11-2016 |
| សរុប | | 2,599,586 | 1,530,202 | 3.080 | 4,712,509 | 58.86 | |
| តួលេខសប្ដាហ៍មុន | | 2,599,586 | 1,191,502 | 2.976 | 3,546,119 | 45.83 | |
| តួលេខឆ្នាំ២០១៥ | | 2,561,957 | 1,477,742 | 2.713 | 4,008,887 | 57.68 | |
| ប្រៀបធៀបឆ្នាំមុន | | 37,629 | 52,460 | 0.367 | 703,622 | 1.18 | |

បានឃើញនិងឯកភាព

ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១៦

ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦ )

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) | | | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | | |
| | | | | ហ.ត | % | ហ.ត | % | | | | | | |
| 01 | បន្ទាយមានជ័យ | 17,870 | 13,086 | - | - | 13,086 | 100.00 | 1 | 30 | 12,030 | 12,060 | 67.49 | 05-12-2016 |
| 02 | បាត់ដំបង | 16,400 | 6,295 | - | - | 6,295 | 100.00 | - | - | 6,295 | 6,295 | 38.38 | 08-12-2016 |
| 03 | កំពង់ចាម | 42,000 | 23,589 | 6,111 | 28.88 | 13,201 | 71.12 | 90 | 627 | 16,014 | 19,199 | 45.71 | 24-11-2015 |
| 04 | កំពង់ឆ្នាំង | 30,700 | 5,400 | - | - | 5,400 | 100.00 | - | - | 5,400 | 5,400 | 17.59 | 06-12-2016 |
| 05 | កំពង់ស្ពឺ | 550 | - | | - | | - | | | | - | - | |
| 06 | កំពង់ធំ | 36,000 | 22,254 | - | - | 22,254 | 100.00 | 12 | 142 | 22,112 | 22,254 | 61.82 | 06-12-2016 |
| 07 | កំពត | 7,000 | 2,237 | - | - | 2,237 | 100.00 | - | - | 2,237 | 2,237 | 31.96 | 05-12-2017 |
| 08 | កណ្ដាល | 55,800 | 15,273 | 1,037 | 6.79 | 14,236 | 93.21 | - | - | 6,653 | 6,653 | 11.92 | 05-12-2016 |
| 09 | កោះកុង | - | - | | - | | - | | | | - | - | |
| 10 | ក្រចេះ | 14,000 | 14,700 | 1,466 | 9.97 | 13,234 | 90.03 | 21 | 88 | 12,232 | 12,320 | 88.00 | 06-12-2016 |
| 11 | មណ្ឌលគិរី | | - | | - | | - | | | | - | - | |
| 12 | ភ្នំពេញ | 1,150 | - | - | - | - | - | - | - | - | - | - | |
| 13 | ព្រះវិហារ | 130 | - | | - | | - | | | | - | - | |
| 14 | ព្រៃវែង | 75,000 | 33,865 | - | - | 33,865 | 100.00 | - | - | 33,865 | 33,865 | 45.15 | 06-12-2016 |
| 15 | ពោធិសាត់ | 9,000 | 7,039 | - | - | 7,039 | 100.00 | - | - | 6,120 | 6,120 | 68.00 | 07-12-2016 |
| 16 | រតនគិរី | | - | | - | | - | | | | - | - | |
| 17 | សៀមរាប | 20,925 | 17,695 | - | - | 17,695 | 100.00 | 20 | 50 | 13,115 | 13,165 | 62.92 | 06-12-2016 |
| 18 | ព្រះសីហនុ | | - | | - | | - | | | | - | - | |
| 19 | ស្ទឹងត្រែង | 100 | - | | - | | - | | | | - | - | |
| 20 | ស្វាយរៀង | 20,000 | 9,239 | - | - | 9,239 | 100.00 | - | - | 8,345 | 8,345 | 41.73 | 06-12-2016 |
| 21 | តាកែវ | 75,000 | 57,550 | 455 | 0.79 | 57,095 | 99.21 | - | - | 26,423 | 26,423 | 35.23 | 06-12-2016 |
| 22 | ឧត្ដរមានជ័យ | 600 | - | | - | | - | | | | - | - | |
| 23 | កែប | 30 | 35 | - | - | 35 | 100.00 | - | - | 35 | 35 | 116.67 | 06-12-2016 |
| 24 | ប៉ៃលិន | 1,000 | - | | - | | - | | | | - | - | |
| 25 | ត្បូងឃ្មុំ | 10,500 | 8,240 | 150 | 1.82 | 8,090 | 98.18 | 75 | 695 | 7,230 | 7,925 | 75.48 | 02-12-2016 |
| | **សរុប** | **433,755** | **236,497** | **9,219** | **3.90** | **223,001** | **94.29** | **219** | **1,632** | **178,106** | **182,296** | **42.03** | |
| | **តួលេខសប្ដាហ៍មុន** | **433,755** | **170,409** | **8,904** | **5.23** | **161,505** | **94.77** | **214** | **1,471** | **122,075** | **123,546** | **28.48** | |
| | **តួលេខឆ្នាំមុន** | **417,325** | **335,435** | **11,312** | **3.37** | **324,123** | **96.63** | **806** | **3,696** | **292,455** | **296,151** | **70.96** | |
| | **ប្រៀបធៀបឆ្នាំមុន** | **16,430** | **-98,938** | **-2,093** | **0.53** | **-101,122** | **-2.33** | **-587** | **-2,064** | **-114,349** | **-113,855** | | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្ដែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 225 | - | 10 | - | 6,250 | 274 | - | - | 1,325 | 424 | 120 | 1 | 7,920 | 709 | 8.95 |
| 02 | បាត់ដំបង | 460 | - | 22 | - | - | - | 50 | 8 | 960 | 110 | 300 | | 1,770 | 140 | 7.91 |
| 03 | កំពង់ចាម | 1,010 | 150 | 1,160 | 480 | 20 | - | 760 | 112 | 2,380 | 1,369 | 150 | 497 | 4,320 | 3,430 | 79.40 |
| 04 | កំពង់ឆ្នាំង | 1,090 | 170 | 70 | - | 90 | 14 | 230 | 30 | 1,860 | 330 | 1,800 | 470 | 5,070 | 914 | 18.03 |
| 05 | កំពង់ស្ពឺ | 4 | - | | | 0 | | 0 | | 190 | | 0 | | 194 | - | - |
| 06 | កំពង់ធំ | 130 | - | 53 | - | 90 | - | 60 | 45 | 345 | 138 | 20 | - | 645 | 236 | 36.59 |
| 07 | កំពត | 200 | - | | | 135 | | 245 | | 590 | 40 | 255 | | 1,425 | 40 | 2.81 |
| 08 | កណ្ដាល | 8,101 | 6,620 | 495 | - | 225 | - | 190 | - | 5,056 | 944 | 4,307 | 169 | 17,879 | 1,608 | 8.99 |
| 09 | កោះកុង | 27 | - | | | 3 | | 5 | | 60 | | - | | 95 | - | - |
| 10 | ក្រចេះ | 1,800 | 1,700 | 1,160 | 934 | - | - | 80 | - | 420 | 192 | 40 | 38 | 2,340 | 1,390 | 59.40 |
| 11 | មណ្ឌលគិរី | - | - | | | - | | - | | - | 474 | - | | - | 474 | - |
| 12 | ភ្នំពេញ | 130 | - | | | - | | - | | 342 | | - | | 472 | - | - |
| 13 | ព្រះវិហារ | - | - | | | - | | - | | 782 | | - | | 782 | - | - |
| 14 | ព្រៃវែង | 1,825 | 1,825 | | | 200 | | 10 | | 790 | | 1,425 | | 4,250 | - | - |
| 15 | ពោធិ៍សាត់ | 200 | 100 | 47 | - | 850 | 74 | 350 | - | 500 | 80 | 300 | 5 | 2,200 | 206 | 9.36 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | 830 | - | 135 | - | 2,490 | 265 | 265 | 125 | 2,040 | 445 | 1,850 | 70 | 7,475 | 1,040 | 13.91 |
| 18 | ព្រះសីហនុ | 35 | | | | 140 | | 20 | | 175 | | | | 370 | - | - |
| 19 | ស្ទឹងត្រែង | 250 | - | 99 | - | - | | - | 34 | 450 | 84 | 500 | 110 | 1,200 | 327 | 27.25 |
| 20 | ស្វាយរៀង | | | | | 7,100 | 261 | 110 | - | 1,170 | 781 | - | | 8,380 | 1,042 | 12.43 |
| 21 | តាកែវ | 232 | - | 109 | - | 398 | 1,698 | 110 | 397 | 648 | 842 | - | 169 | 1,388 | 3,215 | 231.63 |
| 22 | ឧត្តរមានជ័យ | 9 | - | | | 0 | | - | | 65 | | - | | 74 | - | - |
| 23 | កែប | 150 | 30 | 1 | - | 30 | 14 | 100 | | 200 | 7 | - | | 480 | 22 | 4.58 |
| 24 | ប៉ៃលិន | 2,005 | 2,000 | 298 | - | 1,500 | | | | 15 | | 1,000 | 26 | 4,520 | 324 | 7.17 |
| 25 | ត្បូងឃ្មុំ | 5,210 | 8,942 | 1,505 | 1,340 | - | - | 400 | 95 | 1,145 | 330 | 490 | 120 | 10,977 | 2,050 | 14,352 |
| | សរុប | 18,713 | 12,595 | 3,659 | 1,414 | 19,521 | 2,600 | 2,585 | 751 | 11,350 | 6,260 | 12,067 | 1,555 | 73,249 | 15,117 | 20.64 |
| | តួលេខសប្តាហ៍មុន | 18,713 | 12,595 | 2,901 | 1,333 | 19,521 | 1,941 | 2,585 | 629 | 11,350 | 4,009 | 12,067 | 782 | 73,249 | 10,262 | 14.01 |
| | តួលេខឆ្នាំមុន | 10,504 | 188 | 8,291 | 6,242 | 4,174 | 3,412 | 4,116 | 987 | 11,804 | 6,602 | 12,100 | 4,588 | 42,698 | 23,880 | 55.93 |
| | ប្រៀបធៀបឆ្នាំមុន | 8,209 | 12,407 | -4,632 | -4,828 | 15,347 | -812 | -1,531 | -236 | -454 | -342 | -33 | -3,033 | 30,551 | -8,763 | -35.29 |

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | - | | - | | - | | 110 | 105 | - | 35 | - | | 110 | 140 | 127.27 |
| 02 | បាត់ដំបង | 100 | | | | 100 | | 30 | 7 | | | | | 230 | 7 | 3.04 |
| 03 | កំពង់ចាម | 790 | 107 | - | - | 30 | 548 | 360 | - | - | - | 3,380 | - | 4,560 | 655 | 14.36 |
| 04 | កំពង់ឆ្នាំង | 80 | 15 | - | - | 760 | 70 | 60 | 9 | 10 | - | 60 | 5 | 970 | 99 | 10.21 |
| 05 | កំពង់ស្ពឺ | 48 | | - | | - | | - | | - | | - | | 48 | - | - |
| 06 | កំពង់ធំ | 199 | - | - | - | - | - | - | 29 | - | - | - | - | 199 | 29 | 14.57 |
| 07 | កំពត | 205 | | - | | 30 | | 235 | | - | | - | | 470 | - | - |
| 08 | កណ្តាល | 96 | - | 50 | - | 150 | - | 442 | 75 | - | - | - | - | 738 | 75 | 10.16 |
| 09 | កោះកុង | - | | - | | - | | 340 | | - | | - | | 340 | - | - |
| 10 | ក្រចេះ | 120 | 85 | - | - | - | - | 110 | 89 | - | - | - | 83 | 230 | 257 | 111.74 |
| 11 | មណ្ឌលគិរី | - | | - | | - | | - | | - | | - | | - | - | - |
| 12 | ភ្នំពេញ | - | | - | | | | | | | | | | - | - | - |
| 13 | ព្រះវិហារ | - | | - | | - | | - | | - | | - | | - | - | - |
| 14 | ព្រៃវែង | 130 | | - | | 1,025 | | 175 | | - | | - | | 1,330 | - | - |
| 15 | ពោធិ៍សាត់ | 550 | 5 | 50 | - | 200 | - | 720 | 27 | - | | - | | 1,520 | 32 | 2.11 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | - | - | 10 | 10 | 210 | - | 405 | 80 | - | - | - | - | 625 | 90 | 14.40 |
| 18 | ព្រះសីហនុ | | | | | | | 40 | | | | | | 40 | - | - |
| 19 | ស្ទឹងត្រែង | - | | - | | | | | | | | | | - | - | |
| 20 | ស្វាយរៀង | | | | | | | 523 | | | | | | 523 | - | - |
| 21 | តាកែវ | 122 | 71 | - | | 11 | 17 | 175 | 220 | - | - | - | - | 308 | 308 | 100.00 |
| 22 | ឧត្តរមានជ័យ | - | | - | | - | | - | | - | | - | | - | - | - |
| 23 | កែប | 100 | 38 | - | - | - | - | 30 | 138 | - | | - | | 130 | 176 | 135.38 |
| 24 | ប៉ៃលិន | 50 | | | 5 | 100 | | 10 | | | | | | 160 | 5 | 3.13 |
| 25 | ត្បូងឃ្មុំ | 230 | 65 | - | - | - | 45 | 20 | 5 | - | - | 1,340 | 50 | 1,590 | 165 | 10.38 |
| | **សរុប** | **3,624** | **386** | **110** | **15** | **2,616** | **680** | **3,785** | **784** | **10** | **35** | **4,780** | **138** | **14,121** | **2,038** | **14.43** |
| | **តួលេខសប្តាហ៍មុន** | **3,624** | **299** | **110** | **5** | **2,616** | **590** | **3,785** | **667** | **10** | **-** | **4,780** | **48** | **14,121** | **1,609** | **11.39** |
| | **តួលេខឆ្នាំមុន** | **3,624** | **980** | **1,173** | **672** | **2,789** | **242** | **3,735** | **504** | **80** | **-** | **8,930** | **1,829** | **20,331** | **4,227** | **20.79** |
| | **ប្រៀបធៀបឆ្នាំមុន** | **-** | **-594** | **-1,063** | **-657** | **-173** | **438** | **50** | **280** | **-70** | **35.00** | **-4,150** | **-1,691** | **-6,210** | **-2,189** | **-6.36** |

**បានឃើញ និងឯកភាព**

ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១៦

ប្រធានការិយាល័យស្ថិតិ